ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៣-១២០ ប្រ.ក

**ប្រកាស**
**ស្តីពី**
**ការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ**

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋាន

**ស ម្រេ ច**

**ប្រការ១.-**

បង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលតទៅនេះហៅថា "**គណៈកម្មការ**" ។

**ប្រការ២.-**

គណៈកម្មការនេះ រួមមានសមាសភាពចំនួន ៩រូប ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. ឯកឧត្តម ជា ចាន់តូ | ទេសាភិបាល | ប្រធាន |
| ២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ | អគ្គលេខាធិការ | អនុប្រធាន |
| ៣. លោក គិម វ៉ាដា | អគ្គនាយកត្រួតពិនិត្យ | សមាជិក |
| ៤. លោកស្រី ងួន សុខា | អគ្គនាយកបច្ចេកទេស | សមាជិក |
| ៥. លោក រ័ត្ន សុវណ្ណនរៈ | អគ្គនាយករងត្រួតពិនិត្យ | សមាជិក |
| ៦. លោកស្រី សាយ សំអាត | អគ្គនាយករងបច្ចេកទេស | សមាជិក |
| ៧. លោកស្រី គាំ គណ្ឋា | ប្រធាននាយកដ្ឋានប្រតិបត្តិការ | សមាជិក |

| | | |
|---|---|---|
| ៨. លោកស្រី អ៊ុច សុខុម | ប្រធាននាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា | សមាជិក |
| ៩. លោក យូ វណ្ណី | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ ។ |

**ប្រការ ៣.-**

គណៈកម្មការនេះ អាចដំណើរការកិច្ចប្រជុំបានលុះត្រាតែមាន ទេសាភិបាល ជាប្រធាន និងមានសមាជិកយ៉ាងតិចចំនួន ៦រូប ។ សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ។ ប្រធានគណៈកម្មការអាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញផ្សេងទៀត ចូលរួមក្នុងការប្រជុំតាមការចាំបាច់ ។

**ប្រការ ៤.-**

ការប្រជុំរបស់គណៈកម្មការ ត្រូវធ្វើយ៉ាងហោចណាស់រៀងរាល់ពីរខែម្តង ដើម្បីវាយការណ៍ពីស្ថានភាពសេដ្ឋកិច្ច រូបិយវត្ថុ និងហិរញ្ញវត្ថុ ។ ក្នុងករណីមានតម្រូវការចាំបាច់ ប្រធានគណៈកម្មការអាចកោះប្រជុំគណៈកម្មការនៅពេលណាក៏បាន ។

**ប្រការ ៥.-**

គណៈកម្មការមានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- កំណត់និងដឹកនាំការអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ក្នុងក្របខ័ណ្ឌនៃគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល សំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច
- ដាក់ចេញនូវវិធានការចាំបាច់ សំដៅធ្វើឱ្យស្ថានភាពសាច់ប្រាក់ងាយស្រួលក្នុងទីផ្សាររូបិយវត្ថុស្របតាមគោលដៅនៃការរក្សាស្ថិរភាពថ្លៃ
- សម្របសម្រួលទៅតាមលទ្ធភាពជាមួយសមាសធាតុផ្សេងៗនៃក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចពិសេសគោលនយោបាយសារពើពន្ធ សំដៅទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
- សម្របសម្រួលទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិប្រុងប្រយ័ត្ននៃការត្រួតពិនិត្យធនាគារ និង
- ផ្សព្វផ្សាយគោលនយោបាយរូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ ។

**ប្រការ ៦.-**

នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការនេះ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍របស់គណៈកម្មការមានក្រុមការងារជំនួយការមកពីនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៅក្រោមឱវាទរបស់ធនាគារជាតិនៃកម្ពុជា ។ ក្រុមការងារនេះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ។ សមាសភាពក្រុមការងារត្រូវតែងតាំងដោយសេចក្តីបង្គាប់ការ និងមានមុខងារ-ភារកិច្ចដូចខាងក្រោម ៖

- តាមដាន ប្រមូល និងចងក្រងព័ត៌មាននិងទិន្នន័យពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចពិភពលោក តំបន់ និងកម្ពុជា និន្នាការសេដ្ឋកិច្ច ស្ថិតិរូបិយវត្ថុ ដើម្បីបម្រើដល់ការសម្រេចចិត្តរបស់គណៈកម្មការក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រ វិធានការ ឬឧបករណ៍គោលនយោបាយរូបិយវត្ថុ

- វិភាគនិងវាយតម្លៃពីបញ្ហាប្រឈម និងផលប៉ះពាល់ដែលនាំឱ្យមានសម្ពាធអតិផរណា ព្រមទាំងលើកឡើងពីជម្រើសនៃការដោះស្រាយជាគោលនយោបាយ ដើម្បីគណៈកម្មការពិនិត្យនិងសម្រេចចេញជាវិធានការអនុវត្ត និង

- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការប្រជុំរបស់គណៈកម្មការ ផ្ញើជូនទៅថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដើម្បីជ្រាបជាព័ត៌មាននិងសហការអនុវត្ត ។

**ប្រការ ៧.-**

កំណត់ហេតុអង្គប្រជុំគណៈកម្មការ ត្រូវរៀបចំឱ្យរួចស្រេចយ៉ាងយូរមួយសប្តាហ៍ក្រោយពេលប្រជុំ ។

**ប្រការ ៨.-**

ប្រកាសស្តីពីការបង្កើតគណៈកម្មការគោលនយោបាយរូបិយវត្ថុ លេខធ១-០១២-១២៩ ប្រ.ក ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ព្រមទាំងសាមីជននៅក្នុងប្រការ ២ ត្រូវអនុវត្តនូវខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១០.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៣

ទេសាភិបាល

ជា-ចាន់តូ

__កន្លែងទទួល :__
- ដូចប្រការ ២ និងប្រការ ៨
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

__ចម្លងជូន :__
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន "
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "